# ការផ្សព្វផ្សាយអំពី សំណើបង្ហាញចំណាប់អារម្មណ៍

## គម្រោងជម្រុញ ការបង្រួមបញ្ចូលគ្នា នៃ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមបំពង់

# CALL FOR EXPRESSION OF INTEREST

## Promoting the Mergers and Acquisitions (M&A) in the Piped Water Supply Sector

| | |
|---|---|
| កម្មវិធីភាពជាដៃគូ កម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់<br>Cambodia Australia Partnership for Resilient Economic Development (CAPRED) Program | |
| **លេខ**<br>CFA Number | CFA25-0055 |
| **ឈ្មោះគម្រោង**<br>Project Name | គម្រោងជម្រុញ ការបង្រួមបញ្ចូលគ្នា នៃ ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតតាមបំពង់<br>Promoting the Mergers and Acquisitions (M&A) in the Piped Water Supply Sector |
| **ផ្នែក**<br>Domain Name | ហេដ្ឋារចនាសម្ព័ន្ធ<br>Infrastructure |
| **កាលបរិច្ឆេទផុតកំណត់**<br>Closing Date | ថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០២៦<br>30 January 2026 |

## 1. សាវតារ / Background

### 1.1. អំពី CAPRED / About CAPRED

កម្មវិធីភាពជាដៃគូកម្ពុជា អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (CAPRED) គឺជាកម្មវិធីអភិវឌ្ឍន៍ សេដ្ឋកិច្ចដ៏សំខាន់មួយរបស់អូស្ត្រាលីនៅកម្ពុជា ដែលផ្តោតទៅលើការជួយឱ្យកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយភាពធន់បរិយាបន្ន និងនិរន្តភាព។ កម្មវិធីនេះចាប់ផ្តើមពីឆ្នាំ ២០២២ រហូតដល់ ឆ្នាំ២០២៧ និងអាចមានលទ្ធភាពបន្តបន្ថែមរយៈពេល ៣ ឆ្នាំទៀត។ កម្មវិធី CAPRED ទទួលបានមូលនិធិឧបត្ថម្ភដោយ ក្រសួងការបរទេស និងពាណិជ្ជកម្មអូស្ត្រាលី (DFAT) ហើយអនុវត្តដោយក្រុមហ៊ុន Cowater International។ CAPRED គាំទ្រវិស័យបច្ចេកទេសចំនួនបី រួមមាន វិស័យកសិកម្ម និងកែច្នៃកសិផល វិស័យពាណិជ្ជកម្ម ការវិនិយោគ និងការអភិវឌ្ឍសហគ្រាស និងវិស័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ។ និងមានអាទិភាពអន្តរវិស័យបីផ្សេងទៀត រួមមាន សមភាពយេនឌ័រ ពិការភាព និងបរិបន្នសង្គម (GEDSI) ភាពធន់នឹងអាកាសធាតុ និងការគាំទ្រលើគោលនយោបាយ។

The CAPRED Facility is Australia's flagship bilateral economic development program in Cambodia, focusing on economic recovery and resilience until 2027, with a possible three-year extension. Funded by the Department of Foreign Affairs and Trade (DFAT) and implemented by Cowater International, CAPRED supports Cambodia in implementing a range of important economic reforms to support the country's economic transition. These interventions and reforms aim to encourage more productive and inclusive public and private investment, promoting a resilient, inclusive, and sustainable economy (RISE).

CAPRED interventions fall under three technical components: Agriculture and Agro-processing; Trade, Investment and Enterprise Development and Infrastructure Development; and three Cross-Cutting components: Gender Equality, Disability and Social Inclusion (GEDSI); Climate Resilient initiatives, and policy support.

## 1.2. អំពីការជម្រុញ ការបង្រួមបញ្ចូលគ្នា/ About Promoting M&A

ក្នុងរយៈពេលជិតដប់ឆ្នាំចុងក្រោយនេះ វិស័យផ្គត់ផ្គង់ទឹកស្អាតតាមតំបន់ជនបទនៅកម្ពុជា មានការរីកចម្រើនគួរឲ្យកត់សម្គាល់ដោយមានការចូលរួមពីវិនិយោគិនឯកជនជាច្រើន ឬហៅកាត់ថាប្រតិបត្តិករទឹកស្អាតឯកជន។ បច្ចុប្បន្ន ប្រតិបត្តិករទឹកស្អាតឯកជនមានចំនួនជាង ៤០០ បានទទួលអាជ្ញាបណ្ណ និងកំពុងផ្គត់ផ្គង់សេវាទឹកស្អាតដល់ប្រជាជននៅទូទាំងប្រទេស។ ខណៈដែលវិស័យកំពុងវិវត្តទៅមុខ ប្រតិបត្តិករទឹកស្អាតឯកជនមួយចំនួនកំពុងស្វែងរកឱកាសផ្សេងៗមានដូចជាការពង្រីកការផ្គត់ផ្គង់ទៅកាន់តំបន់ដែលមិនទាន់មានហេដ្ឋារចនាសម្ព័ន្ធ និងការរួមបញ្ចូលគ្នា ដែលអាចជួយបង្កើននិរន្តរភាពហិរញ្ញវត្ថុ ពង្រីកការគ្របដណ្តប់បានលឿន និងធ្វើឲ្យប្រតិបត្តិការមានលក្ខណៈត្រឹមត្រូវតាមបច្ចេកទេសប្រកបដោយវិជ្ជាជីវៈ។

ការបង្រួមបញ្ចូលគ្នា និងការទិញលក់នេះ ផ្តល់ឱកាសឲ្យប្រតិបត្តិករពង្រីកខ្លួនធំជាងមុន បង្កើនចំណូលដែលអាចឈានដល់ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងជំនាញបច្ចេកទេសត្រឹមត្រូវ និងធានាធនធានហិរញ្ញវត្ថុដែលអាចផ្តល់លទ្ធភាពក្នុងការធ្វើឲ្យប្រសើរឡើង និងពង្រីកហេដ្ឋារចនាសម្ព័ន្ធប្រើប្រាស់បច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុ និងការកែលម្អការផ្តល់សេវា។

ដោយឈរលើមូលដ្ឋាននៃសន្ទុះនេះ CAPRED នឹងអនុវត្តគម្រោងសាកល្បងមួយក្នុងគោលបំណងជម្រុញប្រតិបត្តិការបង្រួមបញ្ចូលគ្នា និងការទិញលក់ ក្នុងចំណោមប្រតិបត្តិករទឹកឯកជនដែលមានអាជ្ញាបណ្ណទាំងអស់។

### គោលបំណងនៃគម្រោងសាកល្បងនេះរួមមាន៖

- បង្កើនលទ្ធភាពទទួលបានព័ត៌មាន និងកាត់បន្ថយភាពគម្លាតព័ត៌មានរវាងប្រតិបត្តិករទឹកឯកជនដែលជាភាគីទិញ និងភាគីលក់
- បង្កើតនូវចំណេះដឹងដើម្បីផ្តល់ជាធាតុចូលក្នុងការរៀបចំគោលនយោបាយសម្រាប់ការបង្រួបបង្រួមវិស័យ
- ស្វែងរក និងកសាងកម្លាំងស្នូលដ៏សំខាន់ ដើម្បីធ្វើឱ្យមុខងារទីផ្សារដែលខ្វះខាតកន្លងមកឲ្យមានដំណើរការ តាមរយៈប្រតិបត្តិការរួមបញ្ចូលគ្នា និងទិញលក់ (M&A) ដែលទទួលបានជោគជ័យ

Cambodia’s rural clean water sector has grown substantially over the past decade, largely driven by private investment. With more than 400 licensed Private Water Operators (PWOs) delivering essential services across the country, the private sector continues to play a vital role in expanding access to safe water.

As the market evolves, some PWOs are exploring various growth pathways, including expansion to greenfield areas and mergers or acquisitions that can enhance financial sustainability, expand coverage and professionalise operations.

Sector consolidation through M&A offers an opportunity to combine technical expertise, operational experience and financial resources—enabling infrastructure upgrade and expansion, adoption of climate-resilient technologies and improved service delivery.

Building on the momentum, CAPRED will pilot a project aimed at stimulating M&A transactions among licensed PWOs.

**The objectives of this pilot are as follows**:

- Improve access and reduce asymmetric information between buy-side and sell-side PWOs;
- Generate insights to inform policy development for sector consolidation; and
- Explore and build critical mass to activate missing market functions through successful M&A transactions.

## 2. កញ្ចប់គាំទ្រពី CAPRED / CAPRED's potential support package

CAPRED នឹងសហការយ៉ាងជិតស្និទ្ធជាមួយប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជនដែលមានចំណាប់អារម្មណ៍ដើម្បីរៀបចំកញ្ចប់គាំទ្រឲ្យស្របទៅតាមតម្រូវការដែលជួយឱ្យការរួមបញ្ចូល ឬទិញលក់អាចប្រព្រឹត្តទៅបាន។ កញ្ចប់គាំទ្រនេះអាចផ្តល់ការគាំទ្រដូចក្នុងចំណោមខាងក្រោម៖

- ការគាំទ្រ លើការវាយតម្លៃ និងការពិនិត្យលម្អិត (due diligence)
- ការគាំទ្រ លើការរៀបចំផែនការអាជីវកម្ម និងការទទួលបានហិរញ្ញប្បទាន
- ការ ផ្សារភ្ជាប់ រវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជនដែលជា ភាគីលក់ និងភាគីទិញ
- ការគាំទ្រផ្សេងៗទៀត ដែលបានឯកភាព ក្នុងដំណើរការរៀបចំកញ្ចប់គាំទ្រ។

CAPRED will work closely with interested PWOs to co-design tailored support packages that help make merger or acquisition deals possible. Each support package will be shaped around the specific needs of the participating PWOs and may include:

- Advisory support on valuation and due diligence;
- Advisory support on business planning and access to finance;
- Linkages among selling and buying side PWOs; and
- Other targeted assistance agreed during the co-design process.

## 3. ដំណើរការអនុវត្តន៍ / Implementation process

ដំណើរការអនុវត្តន៍ នឹងរួមមានសកម្មភាពសំខាន់ៗដូចខាងក្រោម៖
The implementation process will follow, but not limited to, the activities below:

| សកម្មភាព / Activities |
| --- |
| **ការបង្ហាញចំណាប់អារម្មណ៍ / Expression of Interest**<br><br>• CAPRED ផ្សព្វផ្សាយឲ្យប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជនទាំងអស់ដាក់សំណើបង្ហាញចំណាប់អារម្មណ៍។ ការផ្សព្វផ្សាយនេះនឹងបើករហូតដល់កាលបរិច្ឆេទផុតកំណត់។ CAPRED នឹងរៀបចំកិច្ចប្រជុំសិក្ខាសាលាបង្ហាញព័ត៌មានអំពីគម្រោងនេះ។ ប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជនដែលចាប់អារម្មណ៍ អាចចុះឈ្មោះចូលរួមតាមអ៊ីមែល sinhly.kang@capred.org ឬលេខទូរស័ព្ទ +855 99 223 998។<br>• CAPRED calls for Expressions of Interest from all interested PWOs. The call for applications will remain open until the closing date. CAPRED will conduct a briefing session on this Call for Application. Interested PWOs should register to EoI Briefing Session via sinhly.kang@capred.org or +855 99 223 998. |

## ការជ្រើសរើស / Screening

- CAPRED សូមស្វាគមន៍សំណើបង្ហាញចំណាប់អារម្មណ៍ ពីប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជនទាំងអស់។ ដោយសារគម្រោងនេះជាគម្រោងសាកល្បង មានតែសំណើមួយចំនួនកំណត់ប៉ុណ្ណោះ ដែលនឹងត្រូវបានជ្រើសរើសសម្រាប់ការរៀបចំកញ្ចប់គាំទ្ររួមគ្នា និងឈានដល់លើការទទួលការគាំទ្រណាមួយ។
- សំណើនឹងត្រូវពិនិត្យជាបន្តបន្ទាប់ដើម្បីស្វែងរកប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជនដែលបង្ហាញការប្តេជ្ញាចិត្តខ្ពស់ក្នុងការសហការលើឱកាសក្នុងការរួមបញ្ចូល និងទិញលក់។
- អាទិភាពនឹងផ្តល់ឲ្យប្រតិបត្តិករផ្គត់ផ្គង់ទឹកដែលដឹកនាំដោយស្ត្រី ឬ ស្ថិតនៅតំបន់ងាយរងផលប៉ះពាល់អាកាសធាតុ។
- CAPRED welcomes EOIs from all interested Private Water Operators. Due to the pilot nature of this initiative, only a limited number of EOIs will be selected for detailed co-design and support under this phase.
- CAPRED welcomes EOIs from all interested Private Water Operators interested to buy or sell. CAPRED may facilitate linkages through qualified service providers.
- Submissions will be reviewed on a rolling basis to identify operators who demonstrate a strong commitment and genuine interest to collaborate in exploring merger and acquisition opportunities.
- Preference will be given to women-led PWOs or those operating in areas with high climate vulnerability.

## ការរៀបចំនៃការគាំទ្រ / Co-designing Support

- ប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជនដែលបានជ្រើសរើសនឹងចូលរួមសកម្មជាមួយ CAPRED ដើម្បីកំណត់ប្រភេទ និងវិសាលភាពនៃការគាំទ្រដែលត្រូវការដើម្បីសម្រួលទៅដល់ការរួមបញ្ចូល និងទិញលក់។
- CAPRED មានតួនាទីជួយកាត់បន្ថយហានិភ័យក្នុងការវិនិយោគរបស់ប្រតិបត្តិករ ដោយដោះស្រាយឧបសគ្គជាក់លាក់សម្រាប់ការធ្វើប្រតិបត្តិការទិញលក់។ ប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជននឹងត្រូវចូលរួមបដិភាគជាមួយ CAPRED ក្នុងដំណោះស្រាយដែលបានគិតគូររួមគ្នាក្នុងភាពជាម្ចាស់ពេញលេញ។
- Participating PWOs will actively engage with the CAPRED to determine the type and scope of support needed to facilitate potential M&A deals.
- CAPRED's role is to de-risk investments by addressing specific barriers to transactions. The PWOs will therefore be expected to co-invest in the solutions developed, ensuring full ownership.

## ការស្នើកញ្ចប់គាំទ្រ / Proposed Support Package

- បន្ទាប់ពីការរៀបចំរួមគ្នា CAPRED នឹងផ្តល់សំណើកញ្ចប់គាំទ្រដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជនីមួយៗ ដែលបញ្ជាក់ពីប្រភេទ និងកម្រិតនៃការគាំទ្រ។

- សំណើនេះនឹងត្រូវទទួលការពិនិត្យតាមដំណើរការផ្ទៃក្នុងរបស់ CAPRED រួមទាំងការពិនិត្យសារតារស៊ីជម្រៅ (due diligence) និងការអនុវត្តតាមបទប្បញ្ញត្តិផ្ទៃក្នុងផ្សេងៗ។
- Based on the results of co-designing process, CAPRED will share with each PWO a proposed support package, outlining the type and level of assistance to be provided.
- This proposal will be subject to CAPRED's due diligence and internal compliance procedures.

## ការត្រួតពិនិត្យសារតារស៊ីជម្រៅ ការគ្រប់គ្រងហានិភ័យលើបរិស្ថាន និងសង្គម និងលក្ខខណ្ឌផ្សេងទៀត /

**Due Diligence, Environmental and Social Checks and Other Criteria**

- CAPRED នឹងធ្វើការត្រួតពិនិត្យសារតារស៊ីជម្រៅ (due diligence) និងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម (ESMS) លើប្រតិបត្តិករផ្គត់ផ្គង់ទឹកឯកជន។
- ការត្រួតពិនិត្យសារតារស៊ីជម្រៅរបស់ CAPRED នឹងពិនិត្យលើភាពស្របច្បាប់របស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកនីមួយៗ ក្នុងការចុះកិច្ចសន្យា ការជាប់ពាក់ព័ន្ធនឹងនយោបាយ ដែលអាចបង្កឲ្យមានទំនាស់ផលប្រយោជន៍ (ជាក់ស្តែង ឬ អាចមើលឃើញ) ការអនុវត្តវិធានការប្រឆាំងអំពើពុករលួយ ការប្រឆាំងនឹងភេរវកម្ម ការអនុលោមតាមទណ្ឌកម្មអន្តរជាតិ ការគាំពារផ្សេងៗ និងសមត្ថភាពហិរញ្ញវត្ថុ។
- លក្ខខណ្ឌផ្សេងទៀតរួមមាន៖
  - ការបង្ហាញសុចរិតភាព និងសីលធម៌ខ្ពស់
  - មានការគោរពដល់ ភាពខុសគ្នានៃ វប្បធម៌ យេនឌ័រ សាសនា ជាតិសាសន៍ និងអាយុ
  - អនុវត្តកិច្ច ចំពោះបុគ្គលគ្រប់រូបដោយមិនមានភាពលម្អៀង
  - បំពេញកាតព្វកិច្ចក្នុងការយកចិត្តទុកដាក់ចំពោះ សមភាពយេនឌ័រ ជនមានពិការភាព និង បរិយាបន្នសង្គម និង គោរពគោលនយោបាយមិនអត់អោនចំពោះ អំពើរំលោភបៀតបៀនផ្លូវភេទ។
  - អនុលោមតាមយ៉ាងតឹងរ៉ឹងនូវគោលនយោបាយ ណែនាំ និងបទបញ្ញត្តិ របស់ ប្រទេសអូស្ត្រាលី និង ក្រុមហ៊ុន Cowater រួមមាន ក្រមសីលធម៌ និងគោលនយោបាយការពារកុមារ ក្រមសីលធម៌ទូទៅ គោលនយោបាយការពារពីការរំលោភបៀតបៀនផ្លូវភេទ គោលនយោបាយគ្រប់គ្រងអំពើបន្លំ និងអំពើពុករលួយ (ឧទាហរណ៍ ការទាមទារឲ្យបុគ្គលិក និងដៃគូដែលពាក់ព័ន្ធ រាយការណ៍អំពើដែលសង្ស័យថា មិនអនុលោមតាមគោលការណ៍) និង ការពិចារណាផ្នែកតម្លៃនៃលុយ (Value for Money)
  - អនុលោមតាមច្បាប់ និងគោលនយោបាយសុវត្ថិភាពបរិស្ថាននៃប្រទេសកម្ពុជា និង ប្រទេសអូស្ត្រាលី។
- CAPRED will conduct due diligence checks and environmental and social management system (ESMS) assessment on PWOs.
- CAPRED's due diligence check will screen each PWO's legal capacity to contract, possible political exposure, actual or perceived conflict of interests, policies for anti-corruption and anti-terrorism, compliance with international sanctions, safeguarding procedures and policies, and financial capacity.
- Other eligibility criteria include:
  - Demonstrating integrity and high ethical standards.

- Displaying sensitivity and adaptability to cultural, gender, religious, racial, national, and age differences.
- Treating all people fairly without favouritism.
- Fulfilling obligations to GEDSI sensitivity and maintaining a zero-tolerance policy for sexual harassment.
- Strictly comply with the DFAT and Cowater policies, guidelines, and regulation, including Child Protection Code of Conduct and policy, Code of Conduct, the PSEAH policy, Fraud and Corruption Control Policies (e.g., Policies require all staff and engaged partners to report suspected non-compliant behaviour), and considerations of the Value for Money for the works
- Complying with Cambodia and DFAT's policies, including climate/environmental protection safeguard policies

**ការអនុម័ត និងកិច្ចសន្យា / Approvals and Contracting**

- ប្រតិបត្តិករផ្គត់ផ្គង់ទឹកដែលបំពេញលក្ខខណ្ឌទាំងអស់ និងឆ្លងការត្រួតពិនិត្យសារតារស៊ីជម្រៅរួច នឹងត្រូវចុះកិច្ចសន្យាដៃគូ (Partnership Agreement) ជាមួយ CAPRED។
- PWOs that meet all requirements and successfully pass the due diligence process and value for money investment will be awarded a Partnership Agreement.

## 4. កាលវិភាគសកម្មភាព / Timetable

ការដាក់សំណើ ការត្រួតពិនិត្យ និងការឯកភាពនឹងប្រព្រឹត្តិទៅតាមកាលវិភាគដូចខាងក្រោម៖
The application, evaluation, and approval process will have the following timeframes:

| ល.រ.<br>No | សកម្មភាព<br>Activities | កាលបរិច្ឆេទ<br>Timeline |
|---|---|---|
| 1 | ប្រកាសជាសាធារណៈអំពីការអំពាវនាវការបង្ហាញចំណាប់អារម្មណ៍<br>Public Announcement of the Call for Expression of Interest | ថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ២០២៥<br>03 December 2025 |
| 2 | សិក្ខាសាលាបង្ហាញព័ត៌មាន<br>EoI Briefing Session | ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០២៥<br>17 December 2025 |
| 3 | កាលបរិច្ឆេទផុតកំណត់ស្នើសុំ<br>Deadline for submission of applications | ថ្ងៃទី ៣០ ខែមករា ២០២៦<br>30 January 2026 |

## 5. របៀបដាក់សំណើ / How to Apply

ប្រតិបត្តិករផ្តត់ផ្គង់ទឹកឯកជនដែលមានចំណាប់អារម្មណ៍ សូមបញ្ជូនសំណើបង្ហាញចំណាប់អារម្មណ៍ (ឧបសម្ព័ន្ធទី១) ឲ្យបានត្រឹម **ថ្ងៃទី ៣០ ខែមករា ឆ្នាំ ២០២៦** តាមអ៊ីមែលទៅកាន់ procurement@capred.org ។ ប្រតិបត្តិករក៏អាចជ្រើសរើសក្នុងការដាក់សំណើដែលបានព្រីនរួចដោយដាក់ក្នុងស្រោមសំបុត្របិតជិតរួចផ្ញើមកកាន់ការិយាល័យរបស់ CAPRED ដែលមានអាស័យដ្ឋាន ជាន់ទី១៧ អាគារ ជីអាយអេ (GIA Tower) ផ្លូវ សុភមង្គល កោះពេជ្រ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។ ប្រតិបត្តិករដែលមានចំណាប់អារម្មណ៍ ក៏អាចដាក់សំណើតាមរយៈ QR Code ខាងក្រោមបានផងដែរ។

CAPRED នឹងរៀបចំសិក្ខាសាលាបង្ហាញព័ត៌មានអំពីការអំពាវនាវនេះនៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០២៥ ដើម្បីផ្តល់ព័ត៌មាន និងឆ្លើយតបទៅនឹងសំណួរដែលប្រតិបត្តិករអាចមាន។ សម្រាប់ការចុះឈ្មោះចូលរួម សូមទំនាក់ទំនងលោក កាំង ស៊ីញលី តាមរយៈអ៊ីមែល sinhly.kang@capred.org ឬលេខទូរស័ព្ទ +855 99 223 998។ សំណួរឬព័ត៌មានបន្ថែមអំពីការអំពាវនាវនេះ អាចសួរតាមអ៊ីមែល procurement@capred.org មុន ឬក្រោយសិក្ខាសាលា។

Interested PWOs are invited to submit the application form in Annex 1 **by 30 January 2026** to CAPRED's Procurement through the email address: procurement@capred.org. The application can also be submitted in physical copy enclosed in a sealed envelope to CAPRED's office address: 17th Floor, GIA Tower, Sopheak Mongkol Rd, Koh Pich, Phnom Penh, Cambodia. Physical submission can be made to the procurement team at the CAPRED office address. Interested PWOs are also able to submit the application via the QR code below.

CAPRED will conduct a briefing session on this Call for Application on **17 December 2025** to provide information and answer questions interested PWOs may have. Interested participants can register to attend the briefing session through Mr. KANG Sinh Ly via sinhly.kang@capred.org or +855 99 223 998. CAPRED is also available to answer questions or provide more details on this call for application before and after the workshop. Please email procurement@capred.org.

*Cowater International is an equal opportunity employer, basing employment on merit and qualifications as they relate to professional experience and position expectations. Cowater does not discriminate against any employee or applicant on the basis of race, religion, sex, gender identity, disability, age, or any other basis protected by law. CAPRED aims to have a diverse workforce and a workplace that is supportive of gender equality, disability, and social inclusion. Women, people with disabilities, and other minorities are highly encouraged to apply*